ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គលេខាធិការដ្ឋាន
លេខ.......................សហវ.អល

**សេចក្តីជូនដំណឹង**

**ស្តីពី**

**ការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ផ្នែកគ្រប់គ្រងប្រព័ន្ធកម្មវិធីមេ ១ រូប**
**បម្រើការងារនៅនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គលេខាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជូនដំណឹងដល់សាធារណជន ជ្រាបថា នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា **១ រូប** មកបំពេញការងារផ្នែកគ្រប់គ្រងប្រព័ន្ធកម្មវិធីមេ ដើម្បីចូលរួមសម្របសម្រួល និង គាំទ្រទូទៅ ដល់កិច្ចការងារប្រចាំថ្ងៃរបស់នាយកដ្ឋានក្នុងការផ្តល់សេវាផ្នែកបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ ជូនដល់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ បុគ្គលិកជាប់កិច្ចសន្យា **១ រូប**ខាងលើ ដែលត្រូវជ្រើសរើស ត្រូវមានលក្ខខណ្ឌដូចខាងក្រោម ៖

- មានបរិញ្ញាបត្រវិទ្យាសាស្ត្រកុំព្យូទ័រ ឬ សញ្ញាបត្រសមមូល
- មានបទពិសោធន៍លើការគ្រប់គ្រង Web Hosting ១ ឆ្នាំឡើង ជាការប្រសើរ
- មានចំណេះដឹងលើប្រព័ន្ធប្រតិបត្តិការ Linux និង Unix និង អាចប្រើប្រាស់បាន
- ចេះភាសាខ្មែរ-អក្សរខ្មែរច្បាស់ និង ចេះអាន, សរសេរ និង ធ្វើការទំនាក់ទំនងជាភាសាអង់គ្លេសបាន
- មានបទពិសោធន៍ធ្វើការជាក្រុម និង មានទំនាក់ទំនងល្អក្នុងក្រុមការងារ
- មានសមត្ថភាពគ្រប់គ្រង និង ដោះស្រាយការងារចាំបាច់បន្ទាន់ក្នុងពេលតែមួយ
- មានអត្តចរិតស្លូតបូត, ស្មោះត្រង់, អំណត់អត់ធ្មត់, ឧស្សាហ៍ព្យាយាម និង មានការទទួលខុសត្រូវខ្ពស់ក្នុងការងារ ។

បេក្ខជន ឬ បេក្ខនារីដែលមានចំណាប់អារម្មណ៍ សូមផ្ញើប្រវត្តិរូបសង្ខេប (CV) និង Cover Letter ព្រមទាំងឯកសារពាក់ព័ន្ធមកកាន់នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានអាសយដ្ឋានផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ អគារ "គ" ជាន់ទី ៦ ឬ ផ្ញើមកតាមរយៈអ៊ីមែល itd.info@mef.gov.kh ឱ្យបាន **មុនថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០២២ វេលាម៉ោង ៥:០០ នាទីល្ងាច ។**

ថ្ងៃ ......... ខែ ......... ឆ្នាំ ខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២២

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមក៖
លោកស្រី **នី វឌ្ឍធីតា** តាមរយៈលេខទូរសព្ទ ០៩៣ ៦៩៩ ៩៩៨ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# លក្ខខណ្ឌយោង

សម្រាប់បុគ្គលិកជាប់កិច្ចសន្យាផ្នែកគ្រប់គ្រងប្រព័ន្ធកម្មវិធីមេ **១ រូប**

## សេចក្តីផ្តើម

នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវការជ្រើសរើសបុគ្គលិកជាប់កិច្ច-សន្យា **១ រូប** មកបំពេញការងារផ្នែកគ្រប់គ្រងប្រព័ន្ធកម្មវិធីមេ ដើម្បីចូលរួមសម្របសម្រួល និង គាំទ្រទូទៅ ដល់កិច្ចការងារប្រចាំថ្ងៃរបស់នាយកដ្ឋានក្នុងការផ្តល់សេវាផ្នែកបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ ជូនដល់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## លក្ខខណ្ឌជ្រើសរើស

- មានបរិញ្ញាបត្រវិទ្យាសាស្ត្រកុំព្យូទ័រ ឬ សញ្ញាបត្រសមមូល
- មានបទពិសោធន៍លើការគ្រប់គ្រង Web Hosting ១ ឆ្នាំឡើង ជាការប្រសើរ
- មានចំណេះដឹងលើប្រព័ន្ធប្រតិបត្តិការ Linux និង Unix និង អាចប្រើប្រាស់បាន
- ចេះភាសាខ្មែរ-អក្សរខ្មែរច្បាស់ និង ចេះអាន, សរសេរ និង ធ្វើការទំនាក់ទំនងជាភាសាអង់គ្លេសបាន
- មានបទពិសោធន៍ធ្វើការជាក្រុម និង មានទំនាក់ទំនងល្អក្នុងក្រុមការងារ
- មានសមត្ថភាពគ្រប់គ្រង និង ដោះស្រាយការងារចាំបាច់បន្ទាន់ក្នុងពេលតែមួយ
- មានអត្តចរិតស្លូតបូត, ស្មោះត្រង់, អំណត់អត់ធ្មត់, ឧស្សាហ៍ព្យាយាម និង មានការទទួលខុសត្រូវខ្ពស់ក្នុងការងារ ។

## តួនាទី និង ទំនួលខុសត្រូវ

- រៀបចំ ដំឡើង ត្រួតពិនិត្យ ថែទាំ និង ដោះស្រាយបញ្ហានៃប្រព័ន្ធកម្មវិធីមេ ដូចជា Nginx, Apache HTTP, Apache Tomcat, IIS,...
- សិក្សា និង ស្រាវជ្រាវនូវបច្ចេកវិទ្យាថ្មីៗដែលធ្វើឱ្យសុវត្ថិភាពប្រព័ន្ធកម្មវិធីមេកាន់តែប្រសើរឡើង
- ចុះបំពេញបេសកកម្មទៅតាមបណ្តារាជធានី-ខេត្តតាមការចាត់តាំងរបស់ថ្នាក់ដឹកនាំ
- រៀបចំរបាយការណ៍ប្រចាំថ្ងៃ, ប្រចាំសប្តាហ៍, និង ប្រចាំខែ ឬ ដោយផ្អែកលើតម្រូវការរបស់ថ្នាក់ដឹកនាំ
- ត្រូវបំពេញការងារឱ្យបានល្អ និង ម៉ត់ចត់តាមតួនាទីដូចដែលបានបញ្ជាក់ខាងលើ និង ផ្តល់របាយការណ៍ប្រចាំខែលើវឌ្ឍនភាពការងារ ។

## ការកំណត់ពេលនៃកិច្ចសន្យា

កិច្ចសន្យាត្រូវបានធ្វើឡើងក្នុងរយៈពេល ១ ឆ្នាំម្តង គិតចាប់ពីខែ មករា ដល់ ខែ ធ្នូ នៃឆ្នាំនីមួយៗ ផ្អែកលើសេចក្តីសម្រេចទទួលស្គាល់បុគ្គលិកជាប់កិច្ចសន្យា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលចុះហត្ថលេខាដោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ-ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**ថ្នាក់ដឹកនាំគ្រប់គ្រង**

បុគ្គលិកជាប់កិច្ចសន្យានឹងត្រូវបំពេញតួនាទី និង ភារកិច្ច នៅក្នុងការិយាល័យអភិវឌ្ឍន៍និងនវានុវត្តន៍បច្ចេកវិទ្យាព័ត៌មាន នៃនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ត្រូវរាយការណ៍ជូនថ្នាក់ដឹកនាំតាមឋានានុក្រមដូចខាងក្រោម ÷

| **មុខតំណែង** | **ឈ្មោះ និង តួនាទី** |
|---|---|
| អគ្គលេខាធិការ | ឯកឧត្តម **មាស សុខសេនសាន** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន |
| អគ្គលេខាធិការរង | ឯកឧត្តម **មន្ត ប្រាថ្នា** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន |
| ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន | លោក **អៀច សេដ្ឋា** ប្រធាននាយកដ្ឋាន នៃអគ្គលេខាធិការដ្ឋាន |
| អនុប្រធាននាយកដ្ឋានទទួលបន្ទុក | លោក **ប៊ី ណារិន** អនុប្រធាននាយកដ្ឋានទទួលបន្ទុក |
| ប្រធានការិយាល័យអភិវឌ្ឍន៍និងនវានុវត្តន៍បច្ចេកវិទ្យាព័ត៌មាន | លោក **វ៉ូ ណារុន** ប្រធានការិយាល័យអភិវឌ្ឍន៍និងនវានុវត្តន៍បច្ចេកវិទ្យាព័ត៌មាន |

**ទីតាំងបំពេញការងារ**

ជាទូទៅ បុគ្គលិកជាប់កិច្ចសន្យាត្រូវបំពេញការងារនៅការិយាល័យអភិវឌ្ឍន៍និងនវានុវត្តន៍បច្ចេកវិទ្យាព័ត៌មាន នៃនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន ដែលស្ថិតនៅជាន់ទី៦ នៃអគារ ខ និង អគារ គ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាសយដ្ឋានផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

**បរិក្ខារ និង បរិស្ថានការងារ**

បរិក្ខារការងារ ដូចជាតុការិយាល័យ កៅអី និង សេវាអ៊ីនធឺណិត នឹងត្រូវផ្តល់ជូនសម្រាប់បំពេញការងារ ។ ដោយឡែកបុគ្គលិកជាប់កិច្ចសន្យាអាចប្រើប្រាស់កុំព្យូទ័រយួរដៃ ឬ សម្ភារការិយាល័យផ្ទាល់ខ្លួនផ្សេងទៀតតាមការចាំបាច់របស់ខ្លួន សម្រាប់បំពេញការងារ និង សម្រេចលទ្ធផលការងារប៉ុន្តែត្រូវគោរពគោលការណ៍របស់អង្គភាព ។ បុគ្គលិកជាប់កិច្ចសន្យា មិនអនុញ្ញាតឱ្យធ្វើការងារ និង ទំនាក់ទំនងផ្សេងៗលើការងារផ្ទាល់ខ្លួន ក្រៅពីការងារដែលចាត់តាំងដោយនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃអគ្គ-លេខាធិការដ្ឋានក្នុងកំឡុងម៉ោងការងារនោះឡើយ ។